+855 (0)17774864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សាសាបាសាក់ SA SA BASSAC

# អាគារមនុស្ស
## ដោយ  គង់ វលក្ខណ៍

*«ការចង់ឃើញទីក្រុងបានកើតមានមុននឹងមធ្យោបាយដើម្បីរស់នៅដោយរីករាយនៅក្នុងទីក្រុង ។» - មីសែល ឌឺ គឺតូ*

ស្នាដៃរបស់ គង់ វលក្ខណ៍ ដែលគូរពីធ្យូងនិងទឹកខ្មៅ និងចម្លាក់ធ្វើពីខ្សែលួស មានបំណងបង្កើតនូវអារម្មណ៍ងឿងឆ្ងល់ រីករាយ និងមិនច្បាស់លាស់សម្រាប់ទស្សនិកជន ។ ស្នាដៃនេះលែងបង្កើតបទពិសោធន៍ដែលធ្លាប់តែមាននៅក្នុងវិចិត្រសាលជាទូទៅហើយ ប៉ុន្តែបង្កើតជាទិដ្ឋភាពទីក្រុងមួយដែលប្រកបដោយថាមពល ទីក្រុងក្នុងក្តីស្រម៉ៃតែពោពេញទៅដោយភាពអាប់អួរខ្មៅងងឹត ។ ភាពដែលអាចកើតមានបើតាមវក្ខណ៍ស្រម៉ៃ គឺជាទំនាក់ទំនងបំពេញគ្នាទៅវិញទៅមករវាងស្ថាបត្យកម្ម និងគម្រោងទំនើបកម្មនៃទីក្រុង ព្រមទាំងទំនាក់ទំនងជាមួយប្រជាជន ដែលកំពុងទាញយកអត្ថប្រយោជន៍ពីការអភិវឌ្ឍ ។ នៅក្នុងទំនាក់ទំនងក្រោយនេះ ទីក្រុងបម្រើអោយប្រជាជន ដូចគ្នានឹងប្រជាជនបម្រើអោយទីក្រុងវិញដែរ ។ នៅក្នុងទស្សនវិស័យរបស់វលក្ខណ៍ ប្រជាជននៅក្នុងទីក្រុងពេលខ្លះជាផ្នែកនៃអាគារគឺខ្លួនរបស់ពួកគេបានប្រែក្លាយទៅជាអាគារ ។ ទំនង នេះជាការឆ្លុះបញ្ចាំងពីធម្មជាតិនៃអ្នករស់នៅក្នុងទីក្រុង ដែលជាអ្នកទទួលរងនូវឥទ្ធិពលនៃបរិស្ថានជុំវិញមកលើរាងកាយរបស់ពួកគេ តាមរយៈរបៀបរបបដែលពួកគេរស់នៅ និយាយ និងថែរក្សាខ្លួនគេ ។ យើងត្រូវបានស្ថាបនាឡើងទាំងផ្នែករាងកាយនិងផ្លូវចិត្តដោយសារអាគារទាំងឡាយដែលយើងរស់នៅក្នុង ។ ប៉ុន្តែតួអង្គនៅក្នុងរូបនេះសំឡឹងទៅរកអាកាស ក្នុងនៃស្វែងរកជើងមេឃ...

ភាពស្មុគស្មាញនៃរូបនិងទម្រង់ក្នុងស្នាដៃរបស់វលក្ខណ៍ គឺធ្វើឡើងដោយការសម្រេចចិត្តច្បាស់លាស់ ។ វាជាលទ្ធផលនៃដំណើរការនិងការប្រលូកធ្វើការងារកាន់មានលក្ខណៈតាមអារម្មណ៍ផុសចេញភ្លាមៗជាមួយនឹងវិចិត្រសាលនិងជញ្ជាំងនៃសាល ។ ផ្នែកនីមួយៗឆ្លុះបញ្ចាំងអំពីការសម្រេចចិត្តដ៏ប្រុងប្រយ័ត្នស្តីពីអត្ថន័យនិងសោភ័ណភាព ។ នេះមិនសុបនឹងអ្វីដែលសិល្បករកំពុងពិនិត្យឃើញជាក់ស្តែងនៅក្នុងតថភាពទីក្រុងជុំវិញខ្លួននោះទេ ។ ជម្រើសនៃពណ៌ខ្មៅនិងស គឺជាមធ្យោបាយមួយដើម្បីចៀសចេញពីសារឬក៏អត្ថន័យដែលពាក់ព័ន្ធនឹងពណ៌ ។ ធ្យូងដែលបានគូរនៅលើជញ្ជាំងគឺធ្វើមកពីឈើ ដែលពាក់ព័ន្ធនឹងការកាប់ព្រៃឈើ ខណៈដែលស្នាដៃតម្លើងធ្វើពីធ្យូងនៃត្រឡោកដូងណែនាំអំពីជម្រើសបរិស្ថានសមស្រប ។ ភាពសំខាន់នៃការប្រើប្រាស់សម្ភារៈបែបឆៅទាំងនេះក៏បង្កប់ផងដែរនូវអារម្មណ៍សិល្បៈរបស់វលក្ខណ៍ចំពោះទិដ្ឋភាពទីក្រុង ។ គ្រប់ខ្សែគំនូស ស្រមោល និងស្នាមទាំងឡាយសុទ្ធសឹងតែជាឥរិយាបថនៃទឹកដៃគូរគំនូរបែបខ្សែ ។

អត្ថបទដោយ ផាមេឡា ង្វៀន ខូរី សាកលវិទ្យាល័យខរនែល

**អំពីសិល្បករ៖**

ដោយផ្តោតលើការងារបែបគំនូសខ្សែ និងមានចំណាប់អារម្មណ៍ជាពិសេសលើខ្សែនិងទំនាក់ទំនងរបស់វា គង់ វលក្ខណ៍ កើតឆ្នាំ ១៩៨២ ភ្នំពេញ ត្រូវបានគេស្គាល់ពីគំនូរបែបស្ថាបត្យកម្មពណ៌សខ្មៅរបស់គាត់ ដែលស្តីអំពីទីក្រុងភ្នំពេញបែបពិតក្នុងពេលបច្ចុប្បន្ន និងបែបប្រឌិតឬអនាគត ។ វលក្ខណ៍គឺជាសមាជិកនៃក្រុម ស្ទាវសិល្បៈ និងជាគ្រូបង្រៀនសិល្បៈនៅវិទ្យាល័យ ។ ពិពណ៌ម្នាក់ឯងរបស់គាត់រួមមាន *ជាច្រើនជាន់* នៅវិទ្យាស្ថានភាសាបារាំង ភ្នំពេញ ២០០៩ និង *ពណ៌ខ្មៅ* នៅសណ្ឋាគារដឺឡាប៉េស សៀមរាប ២០០៩ ។

# Humanbuild
## Kong Vollak

*"The desire to see the city preceded the means of satisfying it." - Michel De Certeau*

Kong Vollak's immersive environment of charcoal, ink, and wire forms is intended to create a feeling of wonder, pleasure, and uncertainty in the viewer. This is no longer meant to be experienced as a traditional gallery space, but as an urban landscape both vibrant and ominous, a kind of utopian vision with a dark side.

The possibilities of what could be, as the artist imagines, a complementary relationship between the architecture and urban planning of modernity and a reciprocal relationship with the populace, who reap the expected benefits of development. In such a reciprocal relationship, the city serves the people just as the people serve the city. In Kong's vision, the people in the city are at one with its architecture – their bodies transformed into buildings. Perhaps this is reflective of the nature of urban subjects, who bear the imprint of their environment on their bodies, in the way they carry themselves, in the way they speak, in the care of the self. We are mentally and physically structured by the architectures which we inhabit. Yet these figures in the landscape look to the skies, in search of the horizon…

The chaotic configuration of shapes and forms in Kong's wall drawings and sculptures is deliberate, a result of a increasingly organic and instinctual process and engagement with the space of the gallery and the textures of its walls. Each component reflects a conscious decision about meaning and aesthetics; this is not a parallel to what the artist is witnessing in the urban reality around him. The choice of black on white is a means to deter didactic messages and literal meanings associated with colors. The charcoal used on the walls is derived from wood, alluding to deforestation, while the installation is composed of charcoal rendered from coconut shell, a proposal for ecological alternatives. The importance of using these crude materials also lies in the crafted sensibility of Kong's cityscape, in its lines, shadows, smudges – these are the gestures of the hand that makes the marks.

Text by Pamela Nguyen Corey,
Center for Khmer Studies Research Fellow / Doctoral Candidate
History of Art and Visual Studies, Cornell University

**About the Artist**
Focused on mark making, with particular interest in the line and line interactions, Kong Vollak (b. 1983, Phnom Penh) is known for his black on white architectural and reticular drawings of both the real/present and imagined/future of Phnom Penh. Kong is a member of the artist collective Stiev Selepak and a Teacher of the national high school art curriculum. His solo exhibitions include *Many Floors*, French Institute, Phnom Penh (2009) and *Black*, Hotel de la Paix Arts Lounge, Siem Reap (2009).

# អាគារមនុស្ស
## ដោយ គង់ វលក្ខណ៍

# Humanbuild
## Kong Vollak

14 October - 6 November



*Humanbuild* by Kong Vollak, artist-in-residence
SA SA BASSAC, 25 September – 25 October
Photos Lim Sokchanlina, 2011